ខុមហ្វ្រែល COMFREL

គណៈកម្មាធិការដើម្បីការបោះឆ្នោតដោយសេរី និងយុត្តិធម៌នៅកម្ពុជា (គ.ប.ស.យ)

Committee For Free And Fair Elections In Cambodia (COMFREL)

ទីស្នាក់ការកណ្តាល ផ្ទះលេខ ១៣៨ ផ្លូវ ១២២ សង្កាត់ទឹកល្អក់ ១ ខណ្ឌទួលគោក រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
Central Office: #138, St. 122, Teuk Laak I, Tuol Kork, Phnom Penh, CAMBODIA.
P.O. Box 1145, Tel: (855) 23 884 150/12 942 019, Fax: (855) 23 883 750 E-mail: comfrel@online.com.kh, comfrel@comfrel.org or comfreladmin@online.com.kh, Site : www.comfrel.org

គណៈកម្មាធិការនាយក
BOARD OF DIRECTORS

លោក **ធន សារាយ**
Mr. THUN SARAY
ប្រធានគណៈកម្មាធិការនាយក
និងជាប្រធាន ADHOC

លោក **សុក សំអឿន**
Mr. SOK Sam Oeun
អនុប្រធានគណៈកម្មាធិការនាយក
និងជានាយក CDP

លោក **យឹម ប៉ូ**
Mr. YIM Po អគ្គលេខាធិការ
និង នាយក CCPCR

កញ្ញា **ស៊ុន ចាន់សែន**
Miss. SUN Chansen
ប្រធាន KYA

លោក **មុំ សារិន**
Mr. MOM Sarin
នាយក HRCDO

លោកស្រី **ពឹង យក់ហៀប**
Mr. PEUNG Yok Hiep
នាយិកា LAC

លោកស្រី **ទិច សារាយេត**
Ms. TIV Sarayet
សហនាយិកា WMC

កញ្ញា **សយ សារា វឌ្ឍនី**
Miss. SAY Sara Vathany
នាយិកា CWCC

លោក **គីម សុវណ្ណ**
Mr. KIM Sovann
នាយក VIGILANCE

លោក **អាង ច័ន្ទឫទ្ធិ**
Mr. ANG Chanrith
នាយក KKKHRO

លោក **យង់ គិមអេង**
Mr. YONG Kim Eng
នាយក PDP-Center

លោក **ភួង សិទ្ធិ**
Mr. PHUONG Sith

លោក **សឺន សែត**
Mr. SEN Set

ស.ប្រ.ក.៣/លេខ ២៤/០៩ គ.ប.ស.យ/អ.ក

# សេចក្តីប្រកាសព័ត៌មាន

# ស្តីពី

# លទ្ធផលសិក្ខាសាលាម្ចាស់ឆ្នោតក្នុងការកំណត់លក្ខខណ្ឌសន្ទស្សន៍[១] នៃវិស័យអាទិភាពក្នុងរាជធានីភ្នំពេញ

*ភ្នំពេញ, ថ្ងៃទី ២៣ ខែ វិច្ឆិកា ឆ្នាំ ២០០៩*

ប្រជាពលរដ្ឋប្រមាណ ៨៨នាក់ មកពីគ្រប់ខណ្ឌ និងរាជធានីភ្នំពេញ ដែលមានសិក្ខាកាមស្ត្រីចូលរួម ប្រមាណ ៤៩% បានជួបជុំគ្នានៅក្នុងសិក្ខាសាលាម្ចាស់ឆ្នោតក្នុងការកំណត់លក្ខខណ្ឌសន្ទស្សន៍នៃវិស័យអាទិភាពក្នុងរាជធានីភ្នំពេញ កាលពីថ្ងៃទី ១១ ខែវិច្ឆិកា ឆ្នាំ ២០០៩ ។

សមាជិកក្រុមប្រឹក្សារាជធានីឯកឧត្តម **ព្រហ្ម គន្ធ** បានមានមតិស្វាគមន៍ និងថ្លែងបើកសិក្ខាសាលាថា រាជរដ្ឋាភិបាល បានតាក់តែងកម្មវិធីនយោបាយ ហើយបានដាក់ចេញនូវយុទ្ធសាស្ត្រចតុកោណ ដែលគ្របដណ្តប់សឹងគ្រប់វិស័យ ហើយក៏បានធ្វើការបែងចែកវិស័យអាទិភាពនានារួចជាស្រេច។ ហើយសិក្ខាសាលានេះក៏ជាការរួមចំណែករបស់សង្គមស៊ីវិលដើម្បីផ្សារភ្ជាប់ពីតម្រូវការរបស់ប្រជាពលរដ្ឋក្នុងមណ្ឌលភ្នំពេញទៅអោយមន្ត្រីជាប់ឆ្នោត។

អ្នកតំណាងរាស្ត្រ **សុន ឆ័យ** មណ្ឌលភ្នំពេញបានទទួលយកលទ្ធផលនៃវិស័យអាទិភាពទាំង១០ ហើយមានប្រសាសន៍ថា *"[ ខ្ញុំ] សុំសន្យាក្នុងនាមជាតំណាងរាស្ត្រថា នឹងយកចិត្តទុកដាក់នូវ ចំនុចទាំង១០នេះ,,,,,,, "* ។

ជាលទ្ធផលម្ចាស់ឆ្នោតបានពិភាក្សាកំណត់លក្ខខណ្ឌសន្ទស្សន៍នៃវិស័យអាទិភាពទាំង ១០ ក្នុងរាជធានីភ្នំពេញដូចខាងក្រោម:

| **លក្ខខណ្ឌសន្ទស្សន៍នៃវិស័យអាទិភាពទាំងដប់នៅក្នុងរាជធានី ភ្នំពេញ** |
|---|
| ១) សូមរដ្ឋាភិបាលជួយអនុវត្ត និងពង្រឹងការដាក់ពិន័យដល់បុគ្គលិកសុខាភិបាលដែលធ្វើខុសនឹងក្រមសីលធម៌វិជ្ជាជីវៈ [ទៅតាមច្បាប់ និងក្រម សីលធម៌ដែលមានស្រាប់ ] ព្រមទាំងកាត់បន្ថយតម្លៃ សេវាកម្ម ឬមិនយកប្រាក់ចំពោះ អ្នកក្រីក្រដែលគ្មានលទ្ធភាពបង់ថ្លៃសេវានៅតាមមណ្ឌល សុខភាព ឬមន្ទីរពេទ្យរដ្ឋទាំងអស់នៅក្នុងក្រុងភ្នំពេញ ចាប់ពីឆ្នាំ ២០១០ នេះតទៅ ។ |

[១] ការសន្យាណាដែលមានសូចនាករច្បាស់លាស់-អាចមានជាក់ស្តែង អាចវាស់បានដូចជាការអនុម័តច្បាប់ ការបង្កើត ស្ថាប័ន ឬជាសកម្មភាព ការអនុវត្តអ្វីមួយច្បាស់លាស់ ដោយមានគោលដៅ ពេលវេលា ឬមានចំនួនកំណត់ច្បាស់លាស់ ឬមួយប្រៀបធៀបទៅនឹងអត្រាណាមួយច្បាស់លាស់។

| |
|---|
| ២) សុំបញ្ចុះតម្លៃទឹក និងភ្លើង ក្នុងទីក្រុង និងជាយក្រុង ឱ្យបាន ៣០% នៃតម្លៃបច្ចុប្បន្ន ចាប់ពីដើមឆ្នាំ ២០១០ តទៅ ។ និងសុំឱ្យរាជរដ្ឋាភិបាលជួយបញ្ចុះតម្លៃប្រេងឥន្ធនៈឱ្យមានតម្លៃប្រហាក់ប្រហែល ឬស្មើនឹងតម្លៃប្រេងនៃប្រទេសជិតខាង [ប្រទេសជិតខាងដែលមានតំលៃទាប ] ចាប់ពីដើមឆ្នាំ ២០១០ តទៅ។ |
| ៣) សុំឱ្យរដ្ឋាភិបាលតម្លើងប្រាក់ខែដល់មន្ត្រីរាជការ (វិស័យអប់រំ) ចំនួន ៤០% ក្នុងមួយឆ្នាំ ចាប់ពីឆ្នាំ ២០១០ តទៅ ។ និងសុំឱ្យរដ្ឋាភិបាលមានវិធានការដល់គ្រូបង្រៀន ឱ្យបញ្ឈប់ការទារប្រាក់ក្រៅផ្លូវការពីសិស្ស (ក្រសួងមិនបានកំនត់)អោយបាន១០០% ចាប់ពីឆ្នាំ ២០១០ តទៅ។ |
| ៤) សូមឱ្យរាជរដ្ឋាភិបាលជំរុញការអនុម័ត ច្បាប់ប្រឆាំងនឹងអំពើពុករលួយ ឱ្យបានក្នុងឆ្នាំ ២០១០ ។ |
| ៥) សុំឱ្យស្តារប្រព័ន្ធលូទឹក ដើម្បីកុំឱ្យស្ទះទឹក លិចផ្ទះ លិចផ្លូវ (ទំហំលូ ឱ្យបាន ២ ម) ក្នុងខណ្ឌសែនសុខ ខណ្ឌឬស្សីកែវ ចាប់ពីឆ្នាំ ២០១០ និងបញ្ចប់នៅឆ្នាំ ២០១២ ។ |
| ៦) សូមឱ្យរាជរដ្ឋាភិបាល បង្កើតទីផ្សារការងារឱ្យបានយ៉ាងហោចណាស់ ៥០% ជារៀងរាល់ឆ្នាំ នៃយុវជន និងនិស្សិតបញ្ចប់ការសិក្សា [មហាវិទ្យាល័យ] ចាប់ពីឆ្នាំ ២០១០ តទៅ។ |
| ៧) សុំឱ្យរដ្ឋាភិបាលជំរុញ និងផ្តល់ឱកាសដល់ស្ត្រីឱ្យចូលរួមគ្រប់សកម្មភាពការងារក្នុងសង្គម ពិសេសវិស័យនយោបាយ តាំងពីថ្នាក់ជាតិទៅដល់ថ្នាក់មូលដ្ឋានឱ្យបានពី ៣០ % នៅ ក្នុងនីតិកាលទី ៤ ។ (វិស័យនយោបាយថ្នាក់ជាតិ មាន : រដ្ឋសភា ព្រឹទ្ធសភា ហើយថ្នាក់មូលដ្ឋាន គឺនៅតាមភូមិ ឃុំ ស្រុក) ។ |
| ៨) សុំឱ្យក្រសួងសុខាភិបាលមានវិធានការពង្រឹងការចុះត្រួតពិនិត្យ និងបិទឱសថស្ថានណាដែលគ្មានច្បាប់អនុញ្ញាត និងគ្មានសមត្ថភាពវិជ្ជាជីវៈ នៅក្នុងក្រុងភ្នំពេញទាំងអស់ អោយបានក្នុងឆ្នាំ ២០១០ នេះទៅ ។ |
| ៩) សុំឱ្យរាជរដ្ឋាភិបាលផ្សព្វផ្សាយព័ត៌មានពីអ្វីដែលរដ្ឋាភិបាលបានធ្វើក្នុងព្រះរាជាណាចក្រកម្ពុជា រាល់ ៣ ខែម្តង ដោយផ្សព្វផ្សាយតាមរយៈវិទ្យុ ទូរទស្សន៍ កាសែត និងប្រព័ន្ធ ផ្សព្វផ្សាយ នានា ចាប់ពីថ្ងៃទី ០១ ខែមករា ឆ្នាំ ២០១០ ។ |
| ១០) សុំឱ្យរាជរដ្ឋាភិបាលចេញប័ណ្ណកម្មសិទ្ធិដីធ្លី (ប្លង់រឹង) ជូនដល់ប្រជាពលរដ្ឋ នៅទូទាំងរាជធានីភ្នំពេញ ឱ្យបានគ្រប់គ្រួសារត្រឹមឆ្នាំ ២០១២។ |

សិក្ខាសាលានេះត្រូវបានរៀបចំឡើងដោយគណៈកម្មាធិការខុមហ្វ្រែល សហការជាមួយមជ្ឈមណ្ឌលប្រជាពលរដ្ឋ ដើម្បីអភិវឌ្ឍន៍ (PDP-Center), សមាគមយុវជនខ្មែរ (KYA), អង្គការសហការដើម្បីការអភិវឌ្ឍន៍នៅកម្ពុជា (PADEK), អង្គការអភិវឌ្ឍន៍ និងភាពជាដៃគូក្នុងសកម្មភាព (DPA), មជ្ឈមណ្ឌលអប់រំច្បាប់សំរាប់សហគមន៍ (CLEC) ដែលក្នុងនោះមានការចូលរួមពីម្ចាស់ឆ្នោត ដែលតំណាងឱ្យសហគមន៍ អង្គការមិនមែនរដ្ឋាភិបាលនានា អាជីវករ/ពាណិជ្ជករ មន្ត្រីរាជការ សិស្ស/ និស្សិត កសិករ មកពីខណ្ឌ៧មករា ខណ្ឌដូនពេញ ខណ្ឌមានជ័យ ខណ្ឌឬស្សីកែវ ខណ្ឌដង្កោ ខណ្ឌចំការមន ខណ្ឌសែនសុខ ខណ្ឌទួលគោក និងរាជធានីភ្នំពេញ។

សិក្ខាសាលាម្ចាស់ឆ្នោតនេះ ជាគំនិតបង្កើតថ្មីមួយក្នុងគោលបំណងឱ្យប្រជាពលរដ្ឋដែលជាម្ចាស់ឆ្នោតនៅតាមមណ្ឌលនីមួយៗ:

១) មានការយល់ដឹងពីកម្មវិធីនយោបាយនិងយុទ្ធសាស្ត្រចតុកោណរបស់រាជរដ្ឋាភិបាលជាប់ឆ្នោតឆ្នាំ ២០០៨

២) ចូលរួមក្នុងការកំណត់លក្ខខណ្ឌសន្ទស្សន៍នៃវិស័យអាទិភាពនានា ដែលត្រូវការចាំបាច់ក្នុងមណ្ឌល (ខេត្ត) របស់ខ្លួន

៣) និង លក្ខខណ្ឌសន្ទស្សន៍នៃវិស័យអាទិភាពនានាសម្រាប់មណ្ឌលនីមួយៗ ត្រូវបានចងក្រងជារបាយការណ៍ដែលអាចឱ្យសិក្ខាកាមងាយចងចាំដើម្បីចូលរួមតាមដាន និងជម្រុញការអនុវត្តរបស់រាជរដ្ឋាភិបាល អ្នកតំណាងរាស្ត្រ ក្រុមប្រឹក្សា/ គណៈអភិបាលខេត្ត-រាជធានី ក្នុងការសម្រេចបានលក្ខខណ្ឌសន្ទស្សន៍នៃវិស័យទាំងនោះ។

*សម្រាប់ព័ត៌មានបន្ថែមៗសូមទាក់ទង:*

- លោក **ចំនួ ជារិទ្ធ** អ្នកសម្របសម្រួលផ្នែកព័ត៌មានខុមហ្វ្រែល ទូរស័ព្ទ: ០១២ ៨៤៦ ២១១
- លោក **សុខ ពិទូរ្យ** អ្នកសម្របសម្រួលផ្នែកអង្កេតខុមហ្វ្រែល ទូរស័ព្ទ: ០៨៩ ៥២៥ ៤៤៦